មជ្ឈមណ្ឌលសិក្សានិងអភិវឌ្ឍន៍កសិកម្មកម្ពុជា (អង្គការសេដាក)
ផ្ទះលេខ ១១៩ ផ្លូវ ២៥៧ សង្កាត់ទឹកល្អក់ ១ ខ័ណ្ឌទួលគោក រាជធានីភ្នំពេញ
ប្រអប់សំបុត្រលេខ ១១៨ ទូរស័ព្ទ: ៨៥៥-២៣-៨៨០ ៩១៦ ទូរសារ: ៨៥៥-២៣-៨៨៥ ១៤៦

# សេចក្តីប្រកាសព័ត៌មាន

*Released November 24, 2009*

## កសិករគួរយកចិត្តទុកដាក់ខ្ពស់លើការជ្រើសរើស និងបន្សុទ្ធពូជ ដើម្បីទទួលបានទិន្នផលស្រូវខ្ពស់

មជ្ឈមណ្ឌលសិក្សានិងអភិវឌ្ឍន៍កសិកម្មកម្ពុជា (អង្គការសេដាក) ជាអង្គការមិនមែនរដ្ឋាភិបាលខ្មែរ ឯករាជ្យ មិនស្វែងរកកំរៃផលប្រយោជន៍បុគ្គល និងមិនពាក់ព័ន្ធគណបក្សនយោបាយ។ សេដាក បានត្រូវបង្កើតឡើងនៅឆ្នាំ ១៩៩៧ ក្នុងគោលបំណងពង្រឹងសមត្ថភាព និងភាពជាម្ចាស់របស់កសិករ ក្នុងការកែលំអគុណភាពជីវិតរបស់ខ្លួន និងចូលរួមយ៉ាងសកម្មក្នុងការអភិវឌ្ឍន៍សង្គម"។

ខណៈដែលប្រជាកសិករខ្មែរបាននិងកំពុងតែមមាញឹកជាមួយនឹងការប្រមូលផលស្រូវ នៅរដូវច្រូតកាត់ស្រូវរដូវវស្សាឆ្នាំនេះ មជ្ឈមណ្ឌលសិក្សានិងអភិវឌ្ឍន៍កសិកម្មកម្ពុជា (សេដាក) សង្កេតឃើញថា ប្រជាកសិករខ្មែរនៅមិនទាន់បានយកចិត្តទុកដាក់នៅឡើយ ទៅលើការជ្រើសរើស និងបន្សុទ្ធពូជស្រូវ ដែលជាកត្តាសំខាន់សម្រាប់ការធ្វើស្រែរបស់ពួកគាត់។

" ការជ្រើសរើស និងបន្សុទ្ធពូជបានល្អ នាំឱ្យកសិករទទួលបានទិន្នផលស្រូវខ្ពស់ នៅពេលប្រមូលផលរហូតដល់ទៅ ២០% " នេះបើតាមប្រសាសន៍របស់បណ្ឌិត យ៉ង សាំងកុមារ ប្រធានអង្គការសេដាក។ លោកបណ្ឌិតបន្តថា:"ចាប់ផ្តើមពីពូជស្រូវល្អមួយគ្រាប់ កសិករអាចទទួលបាន ស្រូវរាប់ម៉ឺនគ្រាប់ហើយប្រសិនបើកសិករចេះរើសទុកដាក់ពូជជាប់ជានិច្ចរៀងរាល់ឆ្នាំ នោះផលស្រូវក៏កើនជាប់ជានិច្ចផងដែរ"។

ដោយសារតែរដូវច្រូតកាត់គឺជាពេលវេលាដ៏សមស្របនិងល្អបំផុតក្នុងការជ្រើសរើស និតទុកដាក់ពូជ មជ្ឈមណ្ឌលសិក្សានិងអភិវឌ្ឍន៍កសិកម្មកម្ពុជា (សេដាក) សូមធ្វើការអំពាវនាវដល់ប្រជាកសិករ និងស្ថាប័នពាក់ព័ន្ធ ដែលធ្វើការផ្នែកកសិកម្មទាំងអស់ធ្វើការជម្រុញ អនុវត្តនូវសកម្មភាពចាំបាច់មួយចំនួនដូចខាងក្រោម:

១- ជ្រើសរើស ទុកដាក់ និងបន្សុទ្ធពូជ សម្រាប់ការដាំដុះនៅរដូវខាងមុខ ជាពិសេសរើសយកតែកួរស្រូវណាដែលល្អៗ ហើយទុកពូជដោយមិនចាំបាច់បោក ឬបែនទេគឺទុកទាំងកួរតែម្តង

២- ទប់ស្កាត់កុំឱ្យមានការដុតជញ្ជ្រាំង ក្រោយពីរដូវច្រូតកាត់ប្រមូលផលរួច ពីព្រោះជញ្ជ្រាំងជាប្រភពជីធម្មជាតិដ៏សំខាន់សម្រាប់ដី និងស្រូវ

៣- ចំពោះតំបន់ណាដែលអាចធ្វើបាន គេគួរធ្វើការភ្ជួរលប់ជញ្ជ្រាំង និងដាំដំណាំគ្របដី ដើម្បីបង្កើនជីជាតិដី។ល។

អនុវត្តបាននូវសកម្មភាពខាងលើ កសិករពិតជាទទួលបាននូវទិន្នផលស្រូវកើនឡើង ហើយជីជាតិដីត្រូវបានរក្សាបានល្អ។

**ទំនាក់ទំនង:** សម្រាប់ព័ត៌មានបន្ថែមសូមទំនាក់ទំនង លោក ហ៊ិម ខទៀត: ០១៦ ៩៧៥ ៧១៣

Centre d'Etude et de Développement Agricole Cambodgien (CEDAC)

No 119 St. 257 Sangkat Teuk Laak 1, Khan Toul Kork, Phnom Penh - Cambodia
P.O.Box: 118, Tel.: 855-23-880 916, Fax: 855-23-885-146, E-mail: cedac@online.com.kh